ករណីយកិច្ច នៃ ការអប់រំ

ក្រប់ សង្គម នៅក្នុងលោកកិយ ដែលមាន បេសកកម្ម នៃ ការអប់រំ[1] សំរាប់ បណ្តុះបណ្តាល មនុស្សលោក អោយមាន សមត្ថភាព នៃ ការសម្តែងគំនិត[2] និង ពិចារណាកិច្ច, គំនិតរិះគន់ និង សិល្ប: នៃ ការបង្ហួបបង្ហួម, ជម្រើសដោយហ្មត់ចត់ និង ចេះប្រើប្រាស់ នៃ ព័ត៌មាន ដែលបានទទួល គឺ ជា សង្គម មានការរីកចំរើន។ ជាមួយគ្នាផងដែរ បេសកកម្ម នៃ ការអប់រំ ត្រូវ ប្រជុងប្រជា និង សម្រប មនុស្សលោក អោយត្រូវនឹង ខណ: សង្គម[3] ដែលខ្លួនកំពុងរស់នៅ នៅចំពោះមុខ វប្បធម៌ ពិសេស និង សម័យថ្មី របស់សង្គម។ ការអប់រំ យ៉ាងហ្នឹងហើយ ដែលទុកជា បេសនា[4] នៃ បេតិកភ័ណ្ឌ វប្បធម៌ ថាមវ័ន្ត ពី ទំនាន់ មួយ ទៅ ទំនាន់មួយទៀត។ តែត្រូវដឹងដែរថា ការស្រេកឃ្លាន នៃ ភាពទំនើប ជ្រុល ក្នុង ការអប់រំ វាអាចនឹង ក្លាយ ជា គំនិត ដែលមិនមែនជាធម្មជាតិ និង កញ្ជោត ទៅវិញ។ គំនិត ជា កម្រង (corpus) ចង់ប្ជូ តាមទំនើងចិត្ត អោយត្រូវទំនើប

---

[1] បេសកកម្ម នៃ ការអប់រំ ; mission de l'enseignement។

[2] បណ្តុះបណ្តាល នូវ សមត្ថភាព នៃ ការសម្តែងគំនិត; développer la capacité d'expression។

[3] ខណ:សង្គម ; la société du moment។

[4] បេសនា ឬ ការបញ្ជូន, ការប្រគល់, ការផ្ទេ, transmission។

ករណីយកិច្ច នៃ ការអប់រំ

(ម៉ូត) ជួន វា ផ្ទុយ ស្រឡះ ពី គំនិត ជឿនលឿន។ ទស្សនៈ នៃ សម័យថ្មី ក្នុង ការអប់រំ ជួន វា អាច ជា គ្រោះថ្នាក់ ព្រោះ វា ធ្វើ អោយប្រែប្រួល នូវ អត្តរវត្ត (contenu) នៃ ការអប់រំ គឺថា វា ប្តូរ ទស្សនៈ តាមទំនើងចិត្ត ទៅតាម មនោគមវិជ្ជា មួយស្រេបក់[5] ឬ ទៅតាម អនុភាព នៃ ម៉ូត។ ប្តូរ ជាប្រពន្ធិក[6] ពី បវេណី[7] ទៅ ជា ស្នាដៃអធុនាគត[8] គេអាចចាត់ទុកវាបាន ជា គំនិតប្រតិ កិរិយា។ ដូច្នេះ តួនាទី នៃ ការអប់រំ មិនមែន ត្រូវ ផ្សាយ នូវ ភាពភ្លឺភ្លើ ឬ ល្ងង់ក្តៅ មាន នៅក្នុង បច្ចុប្បន្នកាល អោយវា បន្តរស់ ក្នុង ឧត្តរកាល តែ ត្រូវ អប់រំ ដល់ មនុស្សលោក នូវ គ្រប់ សុវិជ្ជា[9] នៃ មនុស្សជាតិ នាបច្ចុប្បន្ន សំរាប់ កសាង អនាគត ដ៏ល្អប្រសើរមួយ។ ដូច្នេះ ការរស់នៅពី ម្សិលម៉ិញ ជា នរ:អារ្យ:[10] មកដល់ ថ្ងៃនេះ វា ជា ពន្លឺជ័យ សំរាប់ ថ្ងៃស្អែក ព្រោះ ការវិត្តន៍ នៃ អារ្យធម៌ វាត្រូវតែ ដើរស្រេបនឹង ការវិត្តន៍ នៃ ការ អប់រំ ដ៏មធ្យូត ដែលជា ការអប់រំ លុបបំបាត់ នូវ ភាពឥតខ្លឹម សារ មិនត្រឹមត្រូវ និង ការក្លែង នៃ ឧត្តមគតិ សំរាប់ បំផ្លាញ ន

---

[5] មនោគមវិជ្ជា មួយស្រេបក់ ; idéologie du moment។

[6] ប្តូរ ជាប្រពន្ធិក ; changement systématique។

[7] បវេណី ; classique។

[8] ស្នាដៃអធុនាគត ; œuvre contemporaine។

[9] សុវិជ្ជា ; belle science, connaissances utiles។

[10] នរ:អារ្យ: ; humain civilisé។

រ:សង្គម។ ដូច្នេះ ដំណោះស្រាយ ទី១ ដែលត្រូវដោះស្រាយ សំរាប់ ការរីកចំរើន នៃ សង្គម គឺ ការអប់រំជាតិ នោះឯង។

ប្រព័ន្ធ នៃ ការអប់រំជាតិ នៅស្រុកខ្មែរសព្វថ្ងៃ រាងខ្វះ មូលដ្ឋាន នៃ មនុស្សនិយម[11] និង សីលធម៌ ផ្អែកលើ ការសិក្សា អំពី បតិដ្ឋាននិយម នៃ វប្បធម៌ និង វិទ្យាសាស្ត្រ[12] ដែលប្រជាជាតិខ្មែរ ធ្លាប់មាន និង វិទ្យាសាស្ត្រទំនើប មានប្រយោជន៍ ដល់ជាតិ។ មូលដ្ឋាននេះ សំរាប់ យុវជន ទុកជា យោង នៃ សេក្តីទុកចិត្ត ដោយសមតា[13] ព្រោះ ជា ចំណេះចេះដឹង មាន ក្រិះជាតិ ជា តម្លៃ វប្បធម៌ និង សីលធម៌ ជា វិនាយក[14]; ជា ការវិវត្តន៍ តាម តំណាក់ការ ពី គុណភាពល្អ ទៅជា ប្រសើរ នៅក្នុង គោលគំនិត ស្វែងរក គុណភាពឧត្តម ដែល មនុស្សលោក អាចធ្វើបាន; ជា បញ្ជ័យ វប្បធម៌[15] នាំអោយ សង្គមជាតិ ក្លាយ ជា អារ្យ:សង្គម ឬ សង្គម ចំហ។ ការខ្វះចន្លោះ នៅក្នុង ប្រព័ន្ធ នៃ ការអប់រំខ្មែរ ដែលយើង កត់សំគាល់ ខាងលើនេះ រាមកអំពីកត្តា មួយចំនួន ដែលយើង លើកយកវា មក អធិប្បាយ ជាសង្ខេប នៅទីនេះ។

---

[11] មូលដ្ឋាន នៃ មនុស្សនិយម ; base de l'humanisme។

[12] បតិដ្ឋាននិយម នៃ វប្បធម៌ និង វិជ្ជាសាស្ត្រ ; positivisme culturel et scientifique។
Positivisme : ក្រិះនៃចំណេះចេះដឹង ផ្អែកលើ ការពិសោធ និង ការសង្កេតមើល។

[13] សេក្តីទុកចិត្ត ដោយ សមតា ; confiance équilibrée។

[14] វិនាយក ; guide moral។

[15] បញ្ជ័យ វប្បធម៌ ; conquête culturelle។

ករណីយកិច្ច នៃ ការអប់រំ

កត្តា ធំចម្បងមួយ គឺ **មានៈ នៃ ចិត្តគំនិត ផ្តាច់ការ**[16] របស់ អ្នកដឹកនាំ និង អ្នកនយោបាយ ដែល វា អោយ ការអប់រំ មាន លក្ខខ័ណ្ឌ តម្រូវនឹង ការចង់បាន ជាដាច់ខាត នៃ ជនាធិប (le politique)។ ចិត្តគំនិត បែបនេះ វា ពុំអាច អោយមាន ប្រព័ន្ធ នៃ ការអប់រំជាតិ បានឡើយ ព្រោះ សញ្ញាណ នៃ ជាតិ វា ផ្ទុយស្រឡះនឹង ចិត្តគំនិត ផ្តាច់ការ ដែល ជា គំនិត ទុក ជាតិ ជា កម្មសិទ្ធិ ឯកជន ផ្អែកលើ ទស្សនៈ ក្រុមនិយម ចង់យកឈ្នះ ជាដាច់ខាត លើ គំនិត ទុកប្រយោជន៍ជាតិ ជាធំ និង ប្រយោ ជន៍ទូទៅ ជា ការរីកចំរើន នៃ សង្គម។ គំនិត ក្រុមនិយម នេះ នាំ ប្រជាជាតិ ដើរទៅរក អវិជ្ជា ដែលជា មហន្តរាយ ដល់ ប្រជា ពលរដ្ឋ។ កត្តា ខាងលើនេះ នាំអោយ ការអប់រំជាតិ មាន លក្ខ ណៈ ជា ការអប់រំ នៃសិទ្ធានុ[17] ដែល ជា ទម្លាប់ មាន រហូតមក នៅក្នុង ជម្រៅចិត្ត ក្មាន ជីវិតសម្ព័ន្ធភាព (vitalité) ផ្ទុយពី រប្ប ធម៌ជាតិ ដែល ជា រប្បធម៌ ជាថាមវ័ន្ត មួយ ធ្លាប់មាន ឈ្មោះ ល្បីល្បាញ ក្នុងលោកិយ។ ក៏ដូចគ្នានឹង ការអប់រំ នៃ មហាជន ក្មាន ជីវិតសម្ព័ន្ធភាព នៅចំពោះមុខ ការហៀរហូរបាចសាច នៃ រប្បធម៌ បរទេស មកលើ រប្បធម៌ជាតិ ដែល ជា កត្តា បន្ថយ ន្ទូរ តម្លៃជាតិ ទុកវា ជា មូលហេតុ នៃ រញ្ជកម្ម (ការធ្វើអោយ

---

[16] មានៈ នៃ ចិត្តគំនិត ផ្តាច់ការ ; la persistance de la mentalité totalitaire។

[17] ការអប់រំ នៃសិទ្ធានុ ; enseignement dogmatique ; ការអប់រំ ធ្វើអោយមានជំនឿស៊ីប ទៅ លើលិទ្ធិអ្វីមួយ។

ឥតផល) នៃ បញ្ហាខ្មែរ។ មួយវិញទៀត ការអប់រំ នៃ សិទ្ធាន្ត វា លុបបំបាត់ នូវ គំនិត រិះគន់ ដែល ជា កត្តា ប្រមូល នូវ បញ្ហា ជាតិ ដែល មាន នៅក្នុង មូលធន នៃ បញ្ហា នៃ មនុស្សលោក។

កត្តា ដែល បានរៀបរាប់ ខាងលើនេះ វា ជា កត្តា ធ្វើអោយ គាំង ទាំង រឬធម៌ បូរាណ និង សម័យ ព្រោះ វា ធ្វើ១អាក់ខាន នូវ វិត្ថារកម្ម (expansion) នៃ បញ្ហា។ ដូច្នេះ ទោះបី នៅស្រុកខ្មែរ មាន សាលារៀន គ្រប់ ថ្នាក់ សិក្សា ពី បឋមសិក្សា ដល់ ឧត្តម សិក្សា ពាសពេញ នគរ តែ បើ ប្រព័ន្ធ នៃ ការអប់រំជាតិ និង មហាជន នោះ វា គ្រាន់តែជា ម៉ាស៊ីន សំរាប់ ផលិត សញ្ញាប័ត្រ តែ វា មិន រំដោះ បញ្ហាជាតិ ១ មាន សេរីភាព ក្នុង ការសំដែង វិ ស័យមតិ និង ការរិះគន់ គឺ ច្បាស់ជា ប្រជាពលរដ្ឋខ្មែរ មិនអាច មាន កម្លាំង នៃ សេរីភាព បើក ផ្លូវ នៃ ភាពទំនើប សំរាប់ កសាង ប្រជាជាតិ ដោយ ប្រើ មធ្យោបាយ នៃ ពន្លឺបញ្ហា។ សេរី ភាព នេះឯង ជា ឃ្លាំង នៃ ចំណេះចេះដឹង និង បញ្ហា នៃ មនុស្ស ជាតិ។

កង្វះ នៃ ករណីយកិច្ច នៃ ការអប់រំ នៅស្រុកខ្មែរ គឺ មកពីកង្វះ នៃការរីកចំរើន នៃលទ្ធិប្រជាធិបតេយ្យ ក៏ដូចជាផ្ទុយទៅវិញ។ កង្វះ ទាំងពីរនេះ ធ្វើអោយ មានសិកភាព របស់ រណ្ណ: អ្នក ដឹកនាំ ក្រិន ព្រោះ ពួកខ្លួន រក្សា ប្រព័ន្ធ អប់រំ នៃសិទ្ធាន្ត ក្នុង គោលដៅ ធ្វើអោយ ប្រជាពលរដ្ឋ ស្ថិត នៅក្នុង ភាពល្ងង់ក្តៅ តែ ពួកគាត់ ភ្លេចគិតថា បើពួកគាត់ រស់នៅក្នុង សង្គម

ករណីយកិច្ច នៃ ការអប់រំ

អវិជ្ជា គឺ ពួកខ្លួននោះឯង ជា ជនអវិជ្ជា នោះដែរ ព្រោះ ហាន: នៃ ការចេះដឹង របស់ ប្រទេសមួយ វា ឆ្លុះក្រឡប់រស្មី ពី ហាន: នៃ ការចេះដឹង របស់ ប្រជាពលរដ្ឋ។ បើ ប្រជាពលរដ្ឋ ល្ងង់ គឺ ពួកអ្នកដឹកនាំ វាច្បាស់ ជា ល្ងង់ ដូចគ្នា នោះដែរ។ មួយវិញទៀត បើ អំណាចផ្តាច់ការ វា អាច រស់មានជីវិតយូរបាន គឺ ច្បាស់ ជា ការ ចេះដឹង របស់ ប្រជាពលរដ្ឋ ពុំមែន ជា ពន្លឺ នៃ សេរីភាព នោះ ទេ។ ត្រូវ ដឹងថា ទោះបី នៅ ប្រទេសចិនកុម្មុយនិស្ត ដែលជា ប្រទេស អនុវត្ត លទ្ធិផ្តាច់ការ ក៏នៅមាន ចំណែកសំខាន់មួយ នៃ លទ្ធិប្រជាធិបតេយ្យ គឺ គំនិត រិះគន់ វានៅមាន នៅក្នុង ក្រុម អ្នកដឹកនាំកំពូល របស់ បក្សកុម្មុយនិស្តចិន។ នៅស្រុក ខ្មែរ គណបក្សប្រជាជនកម្ពុជា ដែល ជា គណបក្សកាន់អំណាច ទុក ការរិះគន់ ទោះបី នៅក្នុង ជួរ របស់ ពួកខ្លួន ជា ការគំរាម ដល់ ជីវិត របស់ បក្ស តែម្តង។ មានសិកភាព នេះឯង ជា ការ បង្ហាញ នូវ អវិជ្ជន្ធការ (obscurantisme) របស់ អ្នកដឹកនាំបក្ស ជា ជនអសុក្ស។ ហេតុនេះឯង បាន ជា ពួកទាំងនោះ មិនទុក ករណីយកិច្ច នៃ ការអប់រំជាតិ ជា កត្តា ធំចម្បងមួយ នៃ ការ អភិវឌ្ឍន៍ជាតិ។ ពួកគាត់ យកតែ ចំនួន សញ្ញាប័ត្រ មករាប់ ១ ឃើញថា វា មាន ចំនួនច្រើន មាននៅក្នុងប្រទេស តែ ការពិត វាជា ចំនួន សំរាប់ តែ បិទបាំង នូវ អវិជ្ជន្ធការ តែប៉ុណ្ណោះឯង។